# ការី-វិនីក្រីក្រ

នៅស្រុកខ្មែរសព្វថ្ងៃ ពួកអ្នកក្រ ជាការី-វិនី ធ្វើការដ៏លំបាកសំរាប់តែរស់រស់តែប៉ុណ្ណោះ។ ក្រៅតែពីប្រាក់ខែតិចតួច ការី-វិនី គ្មានមានប្រព័ន្ធគាំពារសង្គម ដូចយ៉ាងប្រព័ន្ធសុខភាព, ប្រាក់ឧបត្ថម្ភគ្រួសារ ពីសំណាក់អង្គការសង្គមកិច្ច នៃរដ្ឋាភិបាល។ កង្វះនេះ វាបង្កបញ្ហា នៃការចែករំលែកផលកើតពីការអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលរបបដឹកនាំ គេតែងតែលើកឡើងថាជា សគុណរបស់ខ្លួន។ រូបភាព នៃវឌ្ឍនភាពសព្វថ្ងៃ លាក់ការពិតសង្គម ដែលនៅក្នុងការពិតនោះ វាមានបង្កើតគម្លាតជំ រវាងអ្នកមានមួយក្តាប់នឹងអ្នកក្រមួយនគរ។ សញ្ញា នៃទ្រព្យសម្បត្តិ ស-ម្ភារះរបស់ពួកអ្នកមានមួយចំនួនតូច វាជាភាពក្រអឺត សំរាប់អ្នកក្រ។ ជាពិសេស ទ្រព្យសម្បត្តិ ដែលពួកអ្នកមាន ទទួលបាននោះ វាមិនសមនឹងបាន ព្រោះភាគច្រើនដាច់ខាន វាកើតចេញពី ប្រព័ន្ធពុករលួយ។ នៅក្នុងសង្គមសព្វថ្ងៃ អនុគ្រោះនិយម នៃបក្សពួក វានៅពីលើ គុណូបការះនិយម នៃការី-វិនីមានថ្វីដៃ។ ការី-វិនី ជាកម្មករ ជាអ្នករាជការ ជាឈ្នួញបរិចរ ឬតូប បង្កបង្កើតជាវណ្ណះអ្នកក្រីក្រ នៅក្នុងសង្គម ដឹកនាំដោយពួកមន្ត្រីពុករលួយ និង ឧកញ៉ា ភាគច្រើនមានដើមកំណើតជាចិនយួន។ តែពួកអ្នកក្រីក្រខ្មែរម្ចាស់ស្រុក ក៏ទទួលបានផល នៃការរីកចំរើនដែរគឺ បំណុលរាន់ក កើតពីឥណទានខ្នាតតូច ដើម្បីទិញវត្ថុសម័យដូចយ៉ាង ទូរស័ព្ទដៃ ទូរទស្សន៍ និង ម៉ូតូ ដែលជាមធ្យោបាយគមនាគមន៍នៅក្នុងសង្គមទំនើប៕